**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ...................... .រ.ស.

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩

# សេចក្តីថ្លែងការណ៍

## "រដ្ឋាភិបាលមិនគួរដាក់បន្ទុកដោយបង្កើនពន្ធបន្ថែម និងបង្កើតពន្ធថ្មី ដល់ប្រជាពលរដ្ឋក្នុងពេលមានវិបត្តិសេដ្ឋកិច្ចនោះទេ"

តំណាងរាស្ត្រទាំងបីរូបរបស់គណបក្សសិទ្ធិមនុស្ស " គ.ស.ម " ដែលគេមិនអនុញ្ញាតឱ្យបញ្ចេញមតិក្នុងការប្រជុំរដ្ឋសភាពេញអង្គ យល់ឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១០ ដែលបង្កើតចំណាយរហូតប្រមាណជាងពីរពាន់លានដុល្លារអាមេរិក ហើយដែលដាក់បន្ទុកដោយបង្កើនការយកពន្ធបន្ថែមបន្ទុកលើប្រជាពលរដ្ឋដោយខ្វះសមធម៌ និងមិនសមស្របតាមពេលវេលាដែលប្រជាពលរដ្ឋកំពុងទទួលរងនូវវិបត្តិសេដ្ឋកិច្ចនោះឡើយ ។

តំណាងរាស្ត្រ គ.ស.ម. យល់ឃើញថា ក្នុងកាលៈទេសៈដែលពិភពលោក និងប្រទេសកម្ពុជាកំពុងទទួលរងនូវវិបត្តិសេដ្ឋកិច្ច ក្នុងពេលនេះរដ្ឋាភិបាលគួរតែរកមធ្យោបាយជួយបន្ថយបន្ទុកប្រជាពលរដ្ឋខ្លួនវិញ ។ រដ្ឋាភិបាលគួរតែបង្កើនចំណាយរបស់ រដ្ឋជួយប្រជាពលរដ្ឋលើវិស័យសង្គមកិច្ច ជួយដល់ការពិនិត្យ និងព្យាបាលជម្ងឺ ប្រជាពលរដ្ឋក្រីក្រ ជួយការអប់រំដល់យុវជនជាពិសេសកូនអ្នកក្រជាដើម ។ ឯការរកចំណូលវិញ រដ្ឋាភិបាលមិនគួរប្រមូលថវិកាដោយការបង្កើន និងបង្កើតពន្ធថ្មីដែលជាការបន្ថែមបន្ទុកដល់ប្រជាពលរដ្ឋ ប៉ុន្តែគួរប្រមូលថវិកាពីប្រភពផ្សេងៗដូចជា : កាត់បន្ថយអំពើពុករលួយ កាត់បន្ថយចំនួនទីប្រឹក្សារដ្ឋាភិបាល កាត់បន្ថយចំនួនអាជ្ញាធរផ្សេងៗ កាត់បន្ថយចំនួនឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការដែលមានចំនួនច្រើនហួសហេតុ ជាពិសេសកាត់បន្ថយទៅលើការចំណាយរបស់ទីប្រឹក្សាខ្យល់ក្នុងការចុះបំពេញបេសកកម្ម ព្រមទាំងបង្កើនពន្ធលើកាស៊ីណូ ការប្រមូលថវិកាធនធានរ៉ែឱ្យមានតម្លាភាពជាដើម ។ល។

តំណាងរាស្ត្រ គ.ស.ម. ទាំងបីរូបយល់ឃើញថា ក្នុងសង្គមប្រជាធិបតេយ្យ រដ្ឋាភិបាលគឺជារបស់ប្រជាពលរដ្ឋ ហើយថវិកាជាតិ គឺជាថវិការបស់ប្រជាពលរដ្ឋ ដូច្នេះការចាត់ចែងថវិកាជាតិត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋពីតំណាងប្រជាពលរដ្ឋដោយការពិចារណា យកមតិពីមជ្ឈដ្ឋាននានាផង មិនគួរយកតែមតិរបស់គណបក្សកាន់អំណាចនោះឡើយ ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលបើមិនបានជួយសម្រាលបន្ទុករបស់ប្រជាពលរដ្ឋក្នុងគ្រាដ៏លំបាកពេលមានវិបត្តិសេដ្ឋកិច្ចទេ ក៏មិនគួរបន្ថែមបន្ទុកដោយតម្លើងពន្ធ និងបង្កើតពន្ធថ្មីដល់ប្រជាពលរដ្ឋយើងឡើយ ។ ដូច្នេះអ្នកតំណាងរាស្ត្រគ.ស.ម.មិនបោះឆ្នោតគាំទ្រច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១០នេះ ។ YP

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*

*លេខទូរស័ព្ទ : ០១១ ៧៧៧ ៧៥០*


វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៥៣៥, ២២០ ៦២៨, ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៩